សេចក្តីប្រកាសព័ត៌មានរួមរវាងក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
និងអង្គការសុខភាពពិភពលោក

ភ្នំពេញ, ថ្ងៃទី ៣ ខែ កញ្ញា ឆ្នាំ ២០០៩

## ការរាតត្បាតជាសកលនៃជំងឺផ្តាសាយថ្មី A(H1N1)
## ការចំលងក្នុងស្រុក នៅប្រទេសកម្ពុជា

ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សូមណែនាំដល់សាធារណជនអោយបានជ្រាបថា គិតត្រឹមថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៩ នេះចំនួនករណីនៃជំងឺផ្តាសាយថ្មី A(H1N1) ដែលបានបញ្ជាក់ដោយមន្ទីរពិសោធន៍បានកើនឡើងដល់ ៣១ ករណី។ ករណីទាំងអស់នេះមានជំងឺផ្តាសាយ ដែលស្រដៀងទៅនឹងជំងឺផ្តាសាយតាមរដូវ និង បានជាសះស្បើយទាំងអស់ហើយ។

ទោះបីជា ករណីភាគច្រើនបានឆ្លងវីរុស A(H1N1) នៅក្នុងប្រទេសដទៃ ឬ បានប៉ះផ្ទាល់ជាមួយអ្នកដំណើរ ឥឡូវនេះមានការបញ្ជាក់ថាមានការចំលងជំងឺ ផ្តាសាយថ្មី A(H1N1) នៅក្នុងស្រុក ដែលកំពុងកើតឡើងនៅក្នុងប្រទេសកម្ពុជា។ មានប្រជាពលរដ្ឋកម្ពុជា ៥ នាក់ ត្រូវបានបញ្ជាក់ថា បានឆ្លងវីរុសនេះនៅក្នុងស្រុក ដោយពុំមានប្រវត្តិធ្វើដំណើរ ឬ ប៉ះពាល់ជាមួយអ្នកដំណើរទេ។

មកដល់ថ្ងៃទី ២៨ សីហា ឆ្នាំ ២០០៩ ចំនួនករណីនៃជំងឺផ្តាសាយថ្មី A(H1N1) ដែលបានបញ្ជាក់ដោយអង្គការសុខភាពពិភពលោកមានលើសពី ២០៩,៤៣៨ នាក់ នៅក្នុងប្រទេសជាង ១៨០។ នៅលើសកលលោក អត្រាស្លាប់មានប្រហែល ១ភាគរយ។ ឥឡូវនេះ វីរុសបានរាលដាលយ៉ាងខ្លាំង ដែលប្រទេសទាំងឡាយ មិនត្រូវបានតំរូវអោយរាយការណ៍ ពីករណីម្នាក់ៗទៅអង្គការសុខភាពពិភពលោកទេ។

ក្រសួងសុខាភិបាល នឹងបន្តជូនដំណឹងដល់សាធារណជនអំពីការវិវត្តន៍របស់ជំងឺនេះ តាមរយៈគេហទំព័ររបស់នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង www.cdcmoh.gov.kh។ ចាប់តាំងពីថ្ងៃទី ៣ ខែ កញ្ញា ឆ្នាំ ២០០៩ ការធ្វើបច្ចុប្បន្នភាពនៃស្ថានការណ៍ នឹងត្រូវប្រកាសជារៀងរាល់សប្តាហ៍ និងរួមបញ្ចូលទាំងចំនួនសរុបនៃករណីផងដែរ។

ក្រសួងសុខាភិបាល នឹងបន្តតាមដានស្ថានការយ៉ាងជិតដិត និងស្នើរអោយសាធារណជនសំរាកនៅផ្ទះ ប្រសិនបើមានរោគសញ្ញាដូចជាផ្តាសាយ និងទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍របស់ក្រសួងសុខាភិបាល សំរាប់ដំបូន្មាន និងការណែនាំជាបន្ថែមទៀត។ នៅក្នុងការប្រឹងប្រែង ដើម្បីកាត់បន្ថយការរីករាលដាលជាទ្រង់ទ្រាយនៃជំងឺ នៅក្នុងប្រទេសកម្ពុជា អ្នកដែលត្រូវបានបញ្ជាក់ដោយមន្ទីរពិសោធន៍ ថាមានជំងឺផ្តាសាយថ្មី A(H1N1) នឹងត្រូវបានស្នើរអោយទទួលការព្យាបាល និងការដាក់អោយនៅដោយឡែកនៅផ្ទះ ឬនៅមន្ទីរពេទ្យ សំរាប់រយៈពេល ៧ ថ្ងៃ ដោយគិតចាប់តាំងពីថ្ងៃចេញរោគសញ្ញា។

ក្រសួងសុខាភិបាលកំពុងធ្វើការ ដោយសហការជាមួយក្រសួងនានា ភ្នាក់ងារ និងដៃគូអភិវឌ្ឍន៍ដទៃទៀត ដើម្បីធានាការសំរបសំរួលសកម្មភាពអោយមានប្រសិទ្ធភាព សំរាប់សុខភាពសាធារណៈ និងសុវត្ថិភាព។ វិធានការនានា រួមមានការបន្តការតាមដានរកអ្នកជំងឺ នៅតាមអាកាសយានដ្ឋានអន្តរជាតិទាំងអស់ និងច្រកទ្វារព្រំដែន បង្កើនសមត្ថភាពមន្ទីរពេទ្យ បន្តយុទ្ធនាការអប់រំជាសាធារណៈ និងការរៀបចំ សំរាប់ការបើកបវេសនកាល នៅក្នុងខែ តុលា។

**<u>ការណែនាំសំរាប់សាធារណៈជន</u>**

**<u>ការពារខ្លួនអ្នក និង គ្រួសារអ្នក:</u>**

មធ្យោបាយដ៏មានប្រសិទ្ធភាព សំរាប់ការពារការរីករាលដាលនៃវីរុសជំងឺផ្តាសាយថ្មី A(H1N1) គឺត្រូវអនុវត្តអោយបានល្អ និងជាប្រចាំ នូវអនាម័យខ្លួនប្រាណជាមូលដ្ឋាន និងបង្រៀនកុមារអោយអនុវត្តអនាម័យល្អ :

- ខ្ទប់មាត់ និង ច្រមុះ ជាមួយក្រដាស នៅពេលក្អក ឬ កណ្តាស និង បោះចោលនៅក្នុងធុងសំរាម
- លាងដៃអោយបានញឹកញាប់ ជាមួយសាប៊ូ និងទឹក
- ហាមខាកស្តោះនៅទីសាធារណៈ
- ជៀសវាងប៉ះពាល់ផ្ទាល់ជាមួយអ្នកឈឺ។

**<u>របៀបសំគាល់ជំងឺផ្តាសាយ និង វិធីត្រូវអនុវត្តន៍:</u>**

**រោគសញ្ញានៃជំងឺផ្តាសាយថ្មី** A(H1N1) ស្រដៀងនឹងជំងឺផ្តាសាយតាមរដូវ និងរួមមាន : ក្តៅខ្លាំងលើសពី ៣៨ អង្សាសេ ក្អក ឈឺក្បាល ឈឺសាច់ដុំ ឈឺបំពង់ក ហៀរសំបោរ និងអស់កំលាំង។

រាល់អ្នកមានរោគសញ្ញាទាំងនេះ គួរសំរាកនៅផ្ទះ ជៀសវាងទៅកន្លែងដែលមានមនុស្សកកកុញ និងទាក់ទងទូរសព្ទ័ទាន់ហេតុការណ៍ សំរាប់ដំបូន្មាន និងការណែនាំជាបន្ថែមទៀត។

**ការព្យាបាលគឺដូចទៅនឹងជំងឺផ្តាសាយតាមរដូវ** ហើយរួមមាន : ផឹកទឹកអោយបានច្រើន សំរាកនិងប្រើថ្នាំប៉ារ៉ាសេតាម៉ុល (Paracetamol) ដើម្បីបន្ថយកំដៅ និងការឈឺសាច់ដុំ។

ការចំលងរោគអាចចាប់ផ្តើមពី ១ ថ្ងៃ មុនចេញរោគសញ្ញា រហូត ៧ ថ្ងៃ ក្រោយចេញរោគសញ្ញា។

ករណីភាគច្រើន មិនចាំបាច់ប្រើឱសថប្រឆាំងវីរុសទេ។ សព្វថ្ងៃនេះ ពុំទាន់មានវ៉ាក់សាំងសំរាប់ជំងឺផ្តាសាយថ្មី A(H1N1) នៅឡើយទេ ហើយវ៉ាក់សាំងនេះនឹងមិនមានប្រើប្រាស់ជាទូលាយ នៅក្នុងរយៈពេលខ្លីខាងមុខនេះទេ។

សំរាប់ព័ត៌មានបន្ថែមទៀតអំពីជំងឺផ្តាសាយថ្មី A(H1N1) សូមទាក់ទងមកលេខទូរស័ព្ទទាន់ហេតុការណ៍ :

**១១៥ ( មិនគិតថ្លៃ)**

**០១២ ៤៨៨ ៩៨១**

**០៨៩ ៦៦៩ ៥៦៧**

**សំរាប់ព័ត៌មានបន្ថែមទៀត សូមធ្វើការទាក់ទង :**

**ក្រសួងសុខាភិបាល**

វេជ្ជបណ្ឌិត សុខ ទូច

ទូរស័ព្ទ: +៨៥៥ ០១២ ៨៥៦ ៨៤៨

វេជ្ជបណ្ឌិត លី សុវណ្ណ

ទូរស័ព្ទ: + ៨៥៥ ០១២ ៨២៥ ៤២៤

**អង្គការសុខភាពពិភពលោក**

វេជ្ជបណ្ឌិត Michael O'Leary:

ទូរស័ព្ទ: +៨៥៥ ០២៣ ២១៦ ៦១០

វេជ្ជបណ្ឌិត Nima Asgari:

ទូរស័ព្ទ: +៨៥៥ ០២៣ ២១៦ ៦១០